# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២០

# សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទស្សនកិច្ចប្រព័ន្ធធារាសាស្ត្រ ដែលគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី នៅខេត្តតាកែវ

នៅថ្ងៃអង្គារ ទី២១ ខែកក្កដា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមួយនឹងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម វេង សាខុន និងរដ្ឋមន្ត្រីជាច្រើនរូបទៀត ព្រមទាំង ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា Pablo Kang បានធ្វើទស្សនកិច្ច នៅស្រុកព្រៃកប្បាស ក្នុងខេត្តតាកែវ ដើម្បីមើលការធ្វើបង្ហាញម៉ាស៊ីនកសិកម្មទំនើប និងប្រព័ន្ធធារាសាស្ត្រដែលទើបសង់រួច។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "កសិកម្មនៅតែជាឆ្អឹងខ្នងរបស់សេដ្ឋកិច្ច និងសំណាញ់សុវត្ថិភាព សម្រាប់ប្រជាជនកម្ពុជា។"

"ក្នុងនាមជាមិត្ត និងអ្នកជិតខាង អូស្ត្រាលីបន្ថែមលើការគាំទ្ររាប់ទស្សវត្សមកហើយរបស់ខ្លួនលើកសិកម្មកម្ពុជា កំពុងធ្វើការជួយឱ្យវិស័យនេះឆ្លើយតបនឹងការប៉ះពាល់ពីជំងឺកូវីដ-១៩។ ក្នុងពេលដែលប្រជាជនកម្ពុជាជាច្រើន ប្រឈមមុខនឹងការលំបាក និងភាពមិនច្បាស់លាស់ នៅពេលនេះ អូស្ត្រាលីមានមោទនភាពក្នុងការដើរតួនាទីគាំទ្រសន្តិសុខស្បៀង និងភាពធន់នៃសេដ្ឋកិច្ចរបស់កម្ពុជា ។"

តាស៊ូងគឺជាប្រព័ន្ធធារាសាស្ត្រពេញលេញ សាងសង់ដោយ កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) ដែលគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី។ តាស៊ូងភ្ជាប់ទៅស្ទឹងព្រៃកអំបិល - និងប្រើស្ថានីយ៍បូមតែមួយ ក្នុងការបូមទឹកពីប្រឡាយមេនិងប្រឡាយតាមស្រែ ចំងាយជិត៥០គីឡូម៉ែត្រ ចូលផ្ទាល់មកដីស្រែរបស់កសិករ។

មុនប្រព័ន្ធធារាសាស្ត្រនេះ ត្រូវបានសង់ក្នុងឆ្នាំ២០១៧ ភាគច្រើននៃ៩៧០គ្រួសារកសិករ នៅតាស៊ូង អាចធ្វើស្រែបានតែម្តងក្នុងមួយឆ្នាំ ប្រើប្រាស់ទឹកដែលស្រកទៅវិញបន្ទាប់ពីទឹកជំនន់រាល់ឆ្នាំ។ កសិករពេលនេះអាចធ្វើស្រែបានពីរឬបីដងក្នុងមួយឆ្នាំ បង្កើនចំនូលកសិកម្មរបស់ពួកគេ បានច្រើនជាង

ពីរដង។ ថ្លៃទឹកត្រូវបានកាត់បន្ថយជិតបីដង ហើយទិន្នផលស្រូវជាមធ្យមបានកើន ពី៤ទៅ៥,៥តោន ក្នុងមួយហិកតា។

CAVAC បានសង់ប្រព័ន្ធធារាសាស្ត្របែបនេះ ចំនួន១០ នៅខេត្តតាកែវ ព្រៃវែង និងកណ្តាល ចាប់តាំងពីឆ្នាំ២០១៦។ ជាសរុប ប្រព័ន្ធធារាសាស្ត្រទាំងនេះ ស្រោចស្រពដី ៩.០០០ហិកតា បន្ថែមរាល់ឆ្នាំ និងបានបង្កើនផលិតផលស្រូវបានពីរដង ដែលបង្កើតចំណូលថ្មី ប្រហែល១០លានដុល្លាអាមេរិចដល់កសិករកម្ពុជា ជារៀងរាល់ឆ្នាំ។

CAVAC ធ្វើការជាមួយមន្ទីរធនធានទឹក និងឧតុនិយម ដើម្បីបង្កើតនិងបណ្តុះបណ្តាលសហគមន៍កសិករប្រើប្រាស់ទឹក (FWUCs) ឱ្យទទួលខុសត្រូវ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ នៅពេល ចាប់ផ្តើមប្រើប្រាស់។

អូស្ត្រាលីប្តេជ្ញាចិត្តសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព ដែលបំពេញតម្រូវការរបស់សហគមន៍ដែលប្រើប្រាស់។ ពេលនេះអូស្ត្រាលីកំពុងធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងផ្នែកពាក់ព័ន្ធផ្សេងៗ ដើម្បីយកអ្វីដែលយើងបានរៀនពី CAVAC ទៅធ្វើជាមួយប្រព័ន្ធធារាសាស្ត្រផ្សេងទៀត នៅកម្ពុជា។

បន្ថែមពីលើសេវាកម្មធារាសាស្ត្រប្រកបដោយនិរន្តភាព CAVAC ក៏កំពុងគាំទ្រយន្តតូបនីយកម្មកសិកម្ម លើកទឹកចិត្តការប្រើប្រាស់ពូជដែលមានគុណភាពល្អជាងមុន និងធាតុចូលត្រឹមត្រូវ ព្រមទាំងលើកកំពស់ការវិនិយោគលើដំណាំដែលមានតម្លៃខ្ពស់ និងការកែច្នៃកសិឧស្សាហកម្ម។ យុទ្ធសាស្ត្រទាំងនេះ - អនុវត្តដោយទាំងរាជរដ្ឋាភិបាលកម្ពុជានិងវិស័យឯកជន - ជាគន្លឹះក្នុងការធ្វើទំនើបកម្មកសិកម្មកម្ពុជា ដែលនឹងគាំទ្រភាពធន់នៃសេដ្ឋកិច្ច នៅក្នុងពេលប្រឈមមុខនឹងបញ្ហាជំងឺកូវីដ-១៩។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au



**Photo: Chin Saosereymony**




**Photo: Chin Saosereymony**